**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ...ធ៧៤.០២៦.ជ១១. ស.ង.ហ...

# សេចក្តីជូនដំណឹងបន្ថែម
## ស្តីពី
## អតីតគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ហួយវ័ន ផេ ម.ក

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា អតីតគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ហួយវ័ន ផេ ម.ក បានទទួលអាជ្ញាបណ្ណនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ ដើម្បីធ្វើប្រតិបត្តិការទូទាត់សងប្រាក់ ដែលមិនមានសិទ្ធទទួលប្រាក់បញ្ញើ និងផ្តល់ឥណទានដូចធនាគារនោះទេ។ ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា បានអនុវត្តការត្រួតពិនិត្យជាប្រចាំ ដើម្បីវាយតម្លៃលើអនុលោមភាពនៃប្រតិបត្តិការរបស់គ្រឹះស្ថាន។ ក្រោយពីរកឃើញថា ប្រតិបត្តិការរបស់អតីតគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ហួយវ័ន ផេ ម.ក ពុំអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ធនាគារជាតិនៃកម្ពុជា បានសម្រេចដកហូតអាជ្ញាបណ្ណអតីតគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ហួយវ័ន ផេ ម.ក កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៤។ ក្រុមហ៊ុន រីចឆ៍ & ផាតនើរ បានអនុវត្តនីតិវិធីជម្រះបញ្ជី ដោយបានដោះស្រាយជូនអតិថិជន តាមរយៈការជូនដំណឹងដល់ម្ចាស់បំណុលនិងសាធារណជន ចំនួន ២ លើក ឱ្យមកដាក់ពាក្យស្នើសុំទូទាត់បំណុល ដែលលើកទី១ នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០២៥ និងលើកទី២ នៅថ្ងៃទី៧ ខែមករា ឆ្នាំ២០២៥។ នាថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៥ អតីតគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ហួយវ័ន ផេ ម.ក ត្រូវបានលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្មចប់ជាស្ថាពរ។

ទោះបីជាអតីតគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ហួយវ័ន ផេ ម.ក ត្រូវបានលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្មក៏ដោយ ក៏នៅមានបុគ្គលមួយចំនួនអះអាងថាខ្លួនជាម្ចាស់បំណុល និងមិនទាន់ទទួលបានសំណង។ ក្នុងគោលបំណងការពារផលប្រយោជន៍របស់អតិថិជន ធនាគារជាតិនៃកម្ពុជាបានប្រកាសអញ្ជើញបុគ្គលទាំងនោះឱ្យមកបញ្ជាក់អត្តសញ្ញាណនិងផ្តល់ព័ត៌មានពាក់ព័ន្ធនៅធនាគារជាតិនៃកម្ពុជា កាលពីថ្ងៃទី៨ ដល់ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥។ ធនាគារជាតិនៃកម្ពុជាបានទទួលការចុះឈ្មោះចំនួន ១.២៩៧ រូប ដែលមានទឹកប្រាក់ប្រមាណ ៣១លានដុល្លារអាមេរិក និង ២០លាន ជាទម្រង់ USDT។ ផ្អែកតាមព័ត៌មាននិងឯកសារដែលបានទទួលពីបុគ្គលទាំងនោះ ធនាគារជាតិនៃកម្ពុជាបានពិនិត្យផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់ទៅលើទិដ្ឋភាពផ្នែកច្បាប់ពាក់ព័ន្ធនានា ព្រមទាំងបានប្រជុំពិគ្រោះយោបល់ជាមួយមន្ត្រីជំនាញមកពីក្រសួងស្ថាប័នមួយចំនួន រួមមាន៖ ក្រសួងយុត្តិធម៌ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងគណៈកម្មការចំពោះកិច្ចប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដើម្បីស្វែងរកដំណោះស្រាយ ក្នុងដែនសមត្ថកិច្ចរបស់ធនាគារជាតិនៃកម្ពុជា។ ជាលទ្ធផល ព័ត៌មាននិងឯកសារដែលទទួលបាន ពុំមានមូលដ្ឋានគតិយុត្តិគ្រប់គ្រាន់ដើម្បីឱ្យធនាគារជាតិនៃ



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

កម្ពុជាកំណត់ភាពជាម្ចាស់បំណុលរបស់បុគ្គលទាំងនោះទេ។ អាស្រ័យហេតុនេះ ធនាគារជាតិនៃកម្ពុជា បានផ្ញើលិខិតជូនដំណឹងត្រឡប់ទៅបុគ្គលទាំងនោះ តាមរយៈលិខិតលេខ ធ៣៨.០២៦.៤០៤ ស.ជ.ណ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៦ អំពីលទ្ធផលនៃការសិក្សាខាងលើ ព្រមទាំងបញ្ជាក់ជូនថាបុគ្គលទាំងនោះនៅតែអាចបន្តប្រើប្រាស់សិទ្ធិស្របច្បាប់ក្នុងការស្វែងរកដំណោះស្រាយតាមយន្តការតុលាការ និងច្បាប់ជាធរមាន។

ថ្មីៗនេះ បុគ្គលប្រមាណ ២០០ រូប បានមកបង្ហាញខ្លួននៅមុខទីស្នាក់ការធនាគារជាតិនៃកម្ពុជា ដោយបានអះអាងថាជាម្ចាស់បំណុលរបស់អតីតគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ហួយវ៉ន ផេ ម.ក ដែលមិនទាន់ត្រូវបានទូទាត់។ ដូចករណីខាងលើដែរ ធនាគារជាតិនៃកម្ពុជាស្នើឱ្យបុគ្គលអះអាងទាំងនោះបន្តដោះស្រាយតាមយន្តការតុលាការ និងច្បាប់ជាធរមាន។

ធនាគារជាតិនៃកម្ពុជា តែងតែក្រើនរំលឹកអំពីហានិភ័យនៃទ្រព្យសកម្មគ្រីបតូ ដែលអាចនាំឱ្យមានការខាតបង់ និងជាការទទួលខុសត្រូវផ្ទាល់របស់អ្នកប្រើប្រាស់។ លើសពីនេះ ទ្រព្យសកម្មគ្រីបតូអាចត្រូវបានប្រើប្រាស់ដើម្បីបម្រើសកម្មភាពខុសច្បាប់ ដែលអាចនាំឱ្យអ្នកប្រើប្រាស់ប្រឈមនឹងហានិភ័យផ្នែកច្បាប់។ អាស្រ័យហេតុនេះ សូមសាធារណជន មានការប្រុងប្រយ័ត្នខ្ពស់ និងជៀសឱ្យឆ្ងាយពីការធ្វើប្រតិបត្តិការពាក់ព័ន្ធជាមួយទ្រព្យសកម្មគ្រីបតូ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម សាធារណជន និងអាជ្ញាធរពាក់ព័ន្ធ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ៨រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦


**ទំនាក់ទំនង ៖**

អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា

(៨៥៥) ២៣ ៩៨០ ១៨៤

nbccommunications@nbc.gov.kh | www.nbc.gov.kh

ធនាគារជាតិ នៃកម្ពុជា - National Bank of Cambodia | National Bank of Cambodia

National Bank of Cambodia | nbccambodia

Natonal Bank of Cambodia | nationalbankofcambodia_